# ហេតុអ្វីកម្ពុជានិងចិនបានឈានមកដល់កម្រិតទំនាក់ទំនងខ្ពស់បំផុតក្នុងប្រវត្តិសាស្ត្រប្រទេសទាំងពីរ?

កម្ពុជានិងចិនមានទំនាក់ទំនងជាមួយគ្នាក្នុងប្រវត្តិសាស្ត្រជាង២ពាន់ឆ្នាំកន្លងមកហើយ ដែលនៅពេលនោះមានរូបភាពច្រើនតែទៅលើទំនាក់ទំនងតាមរយៈការធ្វើជំនួញផ្លូវទឹក ការជ្រាបចូលនៃវប្បធម៌ និងការផ្លាស់ប្ដូរជនជាតិចិនចូលមករស់នៅកម្ពុជាជាដើមប៉ុណ្ណោះ។ ចំណែកទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន បានចាប់ផ្ដើមជាផ្លូវការនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៥៨។ សម្ដេចព្រះនរោត្តម សីហនុ និងនាយករដ្ឋមន្ត្រីចិន ឯកឧត្តម ជូ អេនឡាយ បានជួបគ្នា និងកសាងទំនាក់ទំនងមិត្តភាពតាំងពីឆ្នាំ១៩៥៥ នៅពេលដែលមេដឹកនាំទាំងពីរបានចូលរួមនៅក្នុងសន្និសីទបណ្ដាប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងបានឌុង ប្រទេសឥណ្ឌូណេស៊ីមកម្ល៉េះ។ ទោះជាយ៉ាងណាទំនាក់ទំនងល្អរវាងកម្ពុជានិងចិនត្រូវបានកាត់ផ្ដាច់ក្រោយការធ្វើរដ្ឋប្រហាររបស់លោកឧត្តមសេនីយ៍ លន់ នល់ ដែលបានបង្កើតសាធារណរដ្ឋខ្មែរ ប៉ុន្តែទំនាក់ទំនងនេះបានវិលមករកភាពល្អប្រសើរវិញរហូតកម្ពុជាបានក្លាយជាសម្ព័ន្ធមិត្តដ៏ជិតស្និទ្ធរបស់ចិន នៅក្រោយការឡើងកាន់អំណាចរបស់ខ្មែរក្រហមនៅកម្ពុជា។ ទោះជាយ៉ាងណា ទំនាក់ទំនងរវាងកម្ពុជានិងចិន បានផ្លាស់ប្ដូរជាបន្តបន្ទាប់ដោយសារតែសភាពការណ៍នយោបាយ និងស្ថានភាពសង្គ្រាមស៊ីវិលជាបន្តបន្ទាប់នៅក្នុងប្រទេសកម្ពុជា មុននឹងក្លាយជាដៃគូយុទ្ធសាស្ត្រ ដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងក្រោយមកជាកិច្ចសហប្រតិបត្តិការត្បូងពេជ្រនៅឆ្នាំ២០២៣ ចំខួប៦៥ឆ្នាំនៃទំនាក់ទំនងការទូតផ្លូវការរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិន។

នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងយ៉ាងច្បាស់អំពីជំហរនយោបាយដែលកម្ពុជាត្រូវប្រកាន់ខ្ជាប់នៅក្នុងទំនាក់ទំនងអន្តរជាតិជាប្រក្រតីរបស់ខ្លួន ជាមួយនឹងបណ្ដាប្រទេសនានាលើសកលលោក។ ត្រង់វាក្យខណ្ឌទី២ នៃមាត្រា១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបានចែងថា "*ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ* "។ ដោយអនុលោមតាមខ្លឹមសារនៅក្នុងរដ្ឋធម្មនុញ្ញនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនយោបាយផ្អាចម្រុះពណ៌ ដើម្បីពង្រឹង ពង្រីក និងរក្សាទំនាក់ទំនងល្អជាមួយនឹងបណ្ដាប្រទេសជាមិត្តនានាលើសកលលោក ក្នុងគោលដៅស្វែងរកនិងរក្សាឱ្យបាននូវផលប្រយោជន៍ជាតិទាំងនៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គម។ បើទោះបីជាកម្ពុជាបានប្រកាន់យកនូវនយោបាយចម្រុះពណ៌ដោយមិនចាប់ដៃតែជាមួយមហាអំណាចមួយ ហើយប្រានចោលទំនាក់ទំនងជាមួយមហាអំណាចមួយទៀតក្ដី ប៉ុន្តែបច្ចុប្បន្ន ទំនាក់ទំនងកម្ពុជា-ចិន ត្រូវបានគេមើលឃើញថា ហាក់មានភាពលេចធ្លោជាខ្លាំង បើប្រៀបធៀបទៅនឹងទំនាក់ទំនងរវាងកម្ពុជាមួយនឹងមហាអំណាចផ្សេងៗទៀតទាំងនៅក្នុងទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និងវិស័យសន្តិសុខ។

ដើម្បីស្វែងយល់អំពីស្ថានភាពទំនាក់ទំនងកម្ពុជា-ចិននាពេលបច្ចុប្បន្ន គេត្រូវរំឭកបន្តិចអំពីស្ថានភាពនយោបាយនៃប្រទេសកម្ពុជាក្រោយការបង្កើតរាជាណាចក្រទីពីរ តាមរយៈការចាប់បដិសន្ធិនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងការផ្លាស់ប្ដូរស្ថានភាពនៅកម្ពុជាក្រោយឆ្នាំ១៩៩៨។ ជាការពិតណាស់ មិនខុសពីសហរដ្ឋអាម៉េរិក និងបណ្ដារដ្ឋាភិបាលបស្ចិមប្រទេសផ្សេងទៀតនោះទេ រដ្ឋាភិបាលចិនក៏បានផ្ដោតជា

សំខាន់នៃទំនាក់ទំនងជាមួយប្រទេសកម្ពុជា តាមរយៈការពង្រឹងទំនាក់ទំនងជាមួយគណបក្សហ្វ៊ុនស៊ិនប៉ិច ដោយសារតែកិត្តិនាមរបស់សម្តេចព្រះនរោត្តមសីហនុនៅក្នុងឆាកនយោបាយ និងមួយផ្នែកទៀត ក៏ដោយសារសម្តេចព្រះនរោត្តមសីហនុ ជាមេដឹកនាំនយោបាយកម្ពុជាដែលមានសមានចិត្តនិងមានភាពសម្ព័ន្ធភាពជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិនរហូតមក។ ទោះជាយ៉ាងណា ក្រោយការបោះឆ្នោតឆ្នាំ១៩៩៨ ទន្ទឹមនឹងការរក្សាទំនាក់ទំនងជាមួយគណបក្សហ្វ៊ុនស៊ិនប៉ិច រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន ក៏បានចាប់ផ្តើមងាកមកពង្រឹងទំនាក់ទំនងជាមួយនឹងគណបក្សប្រជាជនកម្ពុជា ដែលបានក្លាយជាគណបក្សមានកម្លាំងនយោបាយធំមួយនៅកម្ពុជានាពេលនោះផងដែរ។ ដោយមើលឃើញ វាយតម្លៃច្បាស់អំពីមូលដ្ឋានដ៏រឹងមាំរបស់គណបក្សប្រជាជនកម្ពុជា ក្នុងការរក្សាការគាំទ្រពីប្រជាជនកម្ពុជា ដើម្បីបន្តដឹកនាំរដ្ឋាភិបាលនៅអាណត្តិបន្តជាបន្តបន្ទាប់ គណបក្សកុម្មុយនីស្តចិនបានចាក់គ្រឹះទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយថ្នាក់ដឹកនាំ និងយុវជននៃគណបក្សប្រជាជនកម្ពុជា។ ការពង្រឹងទំនាក់ទំនង និងធ្វើការជាមួយគណបក្សកាន់អំណាចនៅកម្ពុជា គឺជាការត្រួសត្រាយផ្លូវដ៏ល្អរបស់ចិននៅក្នុងការជំរុញទំនាក់ទំនងល្អរវាងចិន និងកម្ពុជារហូតមកដល់សព្វថ្ងៃនេះ។

## ការគាំទ្រគោលនយោបាយចិនតែមួយ

ក្រៅពីហុងកុងដែលចាកផុតពីអាណានិគមអង់គ្លេសកាលពីឆ្នាំ១៩៩៧ ហើយបានស្ថិតមកនៅក្រោមការគ្រប់គ្រងរបស់ចិនវិញ កោះតៃវ៉ាន់ដែលមានទំហំ ៣៦ ១៩៣គីឡូម៉ែត្រក្រឡា មានប្រជាជនរស់នៅជាង២០លាននាក់នោះ ដាច់ខាតចិនត្រូវចាត់ទុកជាដែនកោះមួយរបស់ខ្លួនក្រោមរូបភាព« នយោបាយចិនតែមួយ»។ ចំណុចមួយសំខាន់ជាងគេក្នុងអត្ថន័យនៃ «នយោបាយចិនតែមួយ» រាល់បណ្តាប្រទេសទាំងឡាយណា ដែលចង់មានទំនាក់ទំនងការទូតផ្លូវការជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិន ត្រូវតែកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយនឹងសាធារណរដ្ឋចិន (តៃវ៉ាន់)។

ជាការពិតណាស់ ការប្រកាន់ជំហរគាំទ្រ នយោបាយចិនតែមួយ មិនមែនត្រឹមតែជាឆន្ទៈនិងការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជានោះទេ តែវាក៏ជាការអនុវត្តស្របទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងធម្មនុញ្ញអាស៊ានផងដែរ។ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់ជំពូកទី៤ អំពីរបបនយោបាយ មាត្រា៥៣ វាក្យខណ្ឌទី២ បានចែងថា *"ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធីនិងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក"*។

ចំណែកនៅក្នុងធម្មនុញ្ញអាស៊ាន នៅត្រង់វាក្យខណ្ឌទី៧ នៃបុព្វកថា នៃធម្មនុញ្ញរបស់អាស៊ានបានចែងថា *"ដោយគោរពចំពោះសារៈសំខាន់ជាមូលដ្ឋាននៃមិត្តភាព សហប្រតិបត្តិការ និងគោលការណ៍អធិបតេយ្យភាព សមភាព បូរណភាពទឹកដី ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង គោលការណ៍កុងសង់ស៊ីស និងការឯកភាពគ្នាក្នុងពហុភាព"* ។

បន្ទាប់ពីព្រឹត្តិការណ៍ផ្ទុះអាវុធថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបិទការិយាល័យតំណាងរបស់តៃវ៉ាន់នៅកម្ពុជា (ការិយាល័យសេដ្ឋកិច្ចនិងវប្បធម៌តៃប៉ិ)។ ក្រោយមក

ដើម្បីកសាងទំនាក់ទំនងល្អជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិន រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសគាំទ្រ និងប្រកាន់យក«នយោបាយចិនតែមួយ»ក្នុងទំនាក់ទំនងការទូតរបស់កម្ពុជា។ ក្នុងកិច្ចអនុវត្តការប្រកាសរបស់ខ្លួន ដែលគាំទ្រនិងអនុវត្តនូវ «នយោបាយចិនតែមួយ» តាមសំណើរបស់ប្រទេសចិន កាលពីចុងខែធ្នូ ឆ្នាំ២០០៩ កម្ពុជាបានចាប់បញ្ជូនជនជាតិភាគតិចចិន អ៊ុយហ្គ័រ (Uighur) ចំនួន២០នាក់ទៅកាន់ប្រទេសចិនវិញ នៅខណៈដែលជនជាតិភាគតិចចិនទាំងនោះបានមកស្វែងរកសិទ្ធិជ្រកកោនពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនប្រចាំនៅក្នុងប្រទេសកម្ពុជា (UNHCR)។ នៅឆ្នាំ២០១៤ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថាអំពីការហាមឃាត់មិនឱ្យក្រុមប្រឹក្សាអភិវឌ្ឍពាណិជ្ជកម្មក្រៅប្រទេសរបស់តៃវ៉ាន់ បើកការិយាល័យរបស់ខ្លួននៅរាជធានីភ្នំពេញនោះឡើយ ហើយប្រមុខរាជរដ្ឋាភិបាលកម្ពុជាក៏បានហាមមិនឱ្យមានដាក់ទង់ជាតិតៃវ៉ាន់នៅកម្ពុជានោះដែរ បើទោះបីជាស្ថិតនៅក្នុងថ្ងៃបុណ្យជាតិរបស់តៃវ៉ាន់ក៏ដោយក្តី។ កម្ពុជាបានបង្ហាញជំហរកាន់តែច្បាស់បន្ថែមទៀតរបស់ខ្លួនចំពោះ «នយោបាយចិនតែមួយ» ដោយកាលពីឆ្នាំ២០១៦ ដោយរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចមិនបញ្ជូនជនសង្ស័យមួយក្រុមទៅឱ្យតៃវ៉ាន់តាមការស្នើសុំនោះឡើយ ប៉ុន្តែកម្ពុជាបានបញ្ជូនក្រុមសង្ស័យទាំងនោះទៅឱ្យសាធារណរដ្ឋប្រជាមានិតចិនជំនួសវិញ។

នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៧ ក្នុងពិធីពិសាអាហារសាមគ្គីជាមួយសមាគមខ្មែរ-ចិននៅមជ្ឈមណ្ឌលកោះពេជ្រ សម្តេចតេជោបានមានប្រសាសន៍ថា *«នយោបាយចិនតែមួយគឺជានយោបាយដែលយើងត្រូវគោរពចំពោះអធិបតេយ្យភាពរបស់ចិន ការគោរពអធិបតេយ្យភាពរបស់ចិនមានតម្លៃស្មើនឹងការគោរពអធិបតេយ្យភាពរបស់កម្ពុជាផងដែរ "*។ សម្តេចក៏បានបន្តថា *"ការគោរពអធិបតេយ្យចិន គឺជាចំណុចមួយសំខាន់ណាស់សម្រាប់កម្ពុជា និងសម្រាប់តំបន់អាស៊ីផងដែរ ជាពិសេសអាស៊ីអាគ្នេយ៍ ក្នុងឋានៈអាស៊ានជាដៃគូយុទ្ធសាស្ត្ររបស់ចិន»*។

## ជំហរនយោបាយការបរទេសស្របគ្នា

នៅក្នុងគោលនយោបាយការបរទេសរបស់ប្រទេសទាំងពីរ ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន បានប្រកាន់យកជំហរស្របគ្នានៅក្នុងទំនាក់ទំនងរបស់ខ្លួននៅលើឆាកអន្តរជាតិ។ សម្រាប់កម្ពុជា ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៥៣ ត្រង់វាក្យខណ្ឌទី១ នៃមាត្រា៥៣ បានចែងថា *"ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹត្យអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ ព្រះរាជាណាចក្រកម្ពុជា រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និង ប្រទេសដទៃទៀតទាំងអស់លើពិភពលោក។"* និង វាក្យខណ្ឌទី២ បានចែងថា *"ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក "*។ ចំណែកគោលនយោបាយការបរទេសចិន គឺផ្តោតលើគោលការណ៍បញ្ចសីលាដើម្បីជំរុញការរួមរស់ដោយសន្តិភាពគឺៈ ១. គោរពអធិបតេយ្យភាព និងបូរណភាពទឹកដីគ្នាទៅវិញទៅមក ២. ការមិនឈ្លានពានគ្នា ៣. ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងផងគ្នា ៤. គោលការណ៍សមភាព និងគោរពផលប្រយោជន៍ផងគ្នា និង៥. សន្តិសហវិជ្ជមាន (ការរួមរស់ដោយ

សន្តិភាព)។ គោលការណ៍សំខាន់ៗខាងលើនេះ បានឆ្លុះបញ្ចាំងអំពីជំហរ និងចក្ខុវិស័យរួមគ្នារវាងប្រទេសទាំងពីរនៅក្នុងទំនាក់ទំនងអន្តរជាតិ ដោយផ្តល់តម្លៃខ្ពស់ចំពោះគោលការណ៍សន្តិសហវិជ្ជមាន គោរពអធិបតេយ្យភាព គោរពផលប្រយោជន៍ផងគ្នា និងការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង។ សម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជា ក៏ធ្លាប់បានគូសបញ្ជាក់ថា ចក្ខុវិស័យជាយុទ្ធសាស្ត្រក្នុងបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រការបរទេសរបស់កម្ពុជាគឺ *"ការកែទម្រង់ខាងក្នុង និងការបង្កើតមិត្តនៅក្រៅប្រទេស ដោយផ្អែកលើស្មារតីឯករាជ្យភាព"* ព្រមទាំងបានថ្លែងសង្កត់ធ្ងន់ថា កម្ពុជាចាំបាច់ត្រូវបង្កើតមិត្តជាមួយបណ្តាប្រទេសទាំងអស់ ប៉ុន្តែកម្ពុជានឹងមិនធ្វើសម្បទាន ឬប្រគល់អធិបតេយ្យភាព និងសន្តិសុខជាតិជាថ្នូរនឹងជំនួយបរទេស និង/ឬពាណិជ្ជកម្ម និងការវិនិយោគណាមួយឡើយ។ សម្រាប់ចិនវិញ ក្រៅតែពីគោលនយោបាយចិនតែមួយ ការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ គឺជាមូលដ្ឋានដ៏សំខាន់មួយទៀត នៅក្នុងនយោបាយការបរទេសរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន។ រដ្ឋាភិបាលចិនបានកំណត់ជំហររបស់ខ្លួនថា នៅពេលដែលប្រទេសមួយមានបញ្ហាក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ការជ្រៀតជ្រែកបញ្ហាផ្ទៃក្នុងរបស់ប្រទេសដទៃ ដូចជាការបង្កបញ្ហាដោយការគាំទ្រភាគីម្ខាងវាយប្រហារប្រទេសមួយទៀត គឺជារឿងអសីលធម៌។

**តួនាទីរបស់កម្ពុជាក្នុងតំបន់ និងពិភពលោក**

បន្ថែមពីលើនេះ បើគេឈរលើទស្សនៈរបស់ចិនមើលមកកម្ពុជា នៅក្នុងទំនាក់ទំនងចាក់ទឹកមិនលិចរវាងប្រទេសទាំងពីរ កម្ពុជាបានក្លាយជាកូនសោរគន្លឹះដ៏សំខាន់មួយដែលជាក្តីរំពឹងខ្លាំងសម្រាប់ចិនដើម្បីបញ្ចៀសការប្រឈមមុខដាក់គ្នាដោយតានតឹងរវាងចិននិងអាស៊ានទាំងមូល ក្នុងបញ្ហាជម្លោះសមុទ្រចិនខាងត្បូងជាមួយប្រទេសព្រុយណេ ម៉ាឡេស៊ី វៀតណាម និងហ្វីលីពីន ព្រោះដូចដែលបានដឹងស្រាប់ហើយថា រាល់សេចក្តីសម្រេចចិត្តណាមួយរបស់អាស៊ាន គឺត្រូវឈរនៅលើគោលការណ៍កុងសង់ស៊ីស។ នៅឆ្នាំ២០០២ កម្ពុជាក្នុងនាមជាប្រធានប្តូរវេនរបស់អាស៊ាន និងជាមិត្តរបស់ចិននិងសមាជិកអាស៊ានដែលជាភាគីជម្លោះ បានជំរុញកិច្ចខិតខំប្រឹងប្រែងសម្រេចបានជាឯកច្ឆន្ទរវាងគ្រប់ប្រទេសជាសមាជិកអាស៊ាន ដោយបង្កើតបាននូវសេចក្តីប្រកាសស្តីពីការប្រតិបត្តិសម្រាប់ភាគីជម្លោះក្នុងសមុទ្រចិនខាងត្បូង (Declaration of Conduct for parties in South China Sea Issue : DOC) នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០២ នារាជធានីភ្នំពេញ។ កម្ពុជាក៏បានបន្តជំរុញក្រមប្រតិបត្តិក្នុងបញ្ហាសមុទ្រចិនខាងត្បូង (COC) កំពុងតែបន្តពិភាក្សានិងពង្រឹងបន្ថែមទៀត ក្នុងការដោះស្រាយក្នុងវិវាទអធិបតេយ្យភាពនេះ ក្នុងទិសដៅរក្សាសន្តិភាព និងស្ថិរភាពក្នុងដែនសមុទ្រចិនខាងត្បូង។ កម្ពុជាបានជំទាស់នូវការប៉ុនប៉ងដោះស្រាយទាំងឡាយណា ដែលមិនមានការយល់ស្របគ្នាជាឯកច្ឆន្ទ រវាងគ្រប់ភាគីទាំងអស់នៅក្នុងជម្លោះនេះ។ នៅឆ្នាំ២០១២ ក្នុងកិច្ចប្រជុំកំពូលអាស៊ាននៅរាជធានីភ្នំពេញ ក្នុងខណៈដែលកម្ពុជាបានក្លាយជាប្រធានប្តូរវេនរបស់អាស៊ាន កិច្ចប្រជុំនៅពេលនោះអាស៊ានមិនបានចេញសេចក្តីថ្លែងការណ៍ណាមួយឡើយ ព្រោះដោយសារគ្រប់ភាគីទាំងអស់មិនមានការឯកភាពគ្នាទៅលើរបៀបវារៈ ឬការសម្រេចណាមួយស្តីពីសមុទ្រចិនខាងត្បូងឡើយ។ នៅឆ្នាំនោះ កម្ពុជាបានបញ្ចៀសដោយជោគជ័យនូវស្ថានភាព ដែលបណ្តាប្រទេសជាសមាជិកអាស៊ានជាភាគីក្នុងជម្លោះសមុទ្រចិនខាងត្បូង ព្យាយាមទាញសមាជិកដទៃផ្សេងទៀតឱ្យធ្លាក់ចូលទៅក្នុងការប្រឈមមុខដាក់គ្នារវាងអាស៊ាននិងចិន ក្នុងបញ្ហាជម្លោះបូរណភាពដែនដីរបស់ខ្លួន។

## ជំនួយចិនមិនមានលក្ខខណ្ឌចាក់ស្រេះច្រើន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ធ្លាប់បានថ្លែងសុន្ទរកថា នៅក្នុងឆ្នាំ២០០៦ ថា «ប្រទេសចិននិយាយតិច ប៉ុន្តែធ្វើច្រើន» ដោយក្នុងនោះគេឃើញថា ខុសពីជំនួយដែលផ្តល់ដោយបស្ចិមប្រទេស ដែលផ្តោតសំខាន់ទៅលើប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជំនួយរបស់ចិនមកកាន់កម្ពុជា ពុំមានចងភ្ជាប់ជាមួយនូវលក្ខខណ្ឌច្រើននោះទេ ហើយជំនួយរបស់ចិនបានបើកលទ្ធភាពទូលាយដល់កម្ពុជា ក្នុងការយកមូលនិធិនោះទៅប្រើប្រាស់ដោយសិទ្ធិស្វ័យសម្រេចផ្ទាល់ខ្លួន។ ជាការពិតណាស់ កម្ពុជាពិតជាត្រូវការជំនួយពីបណ្តាប្រទេសជាមិត្តដើម្បីយកមកធ្វើការអភិវឌ្ឍសង្គមជាតិរបស់ខ្លួន ក៏ប៉ុន្តែការដាក់លក្ខខណ្ឌកំហិតនានាដូចជា ការជំរុញឱ្យអនុវត្តប្រជាធិបតេយ្យ និងពង្រឹងការគោរពសិទ្ធិមនុស្សទៅតាមទស្សនៈយល់ឃើញរបស់បស្ចិមប្រទេស ត្រូវបានប្រមុខរាជរដ្ឋាភិបាលកម្ពុជាយល់ឃើញថា ហាក់បីដូចជាការយកជំនួយមកដោះដូរជាមួយនឹងអនុវត្តតាមការបង្គាប់បញ្ជារបស់បស្ចិមប្រទេស ក្នុងការរៀបចំសណ្តាប់ធ្នាប់ប្រជាធិបតេយ្យនៅកម្ពុជាតាមការចង់បានរបស់ម្ចាស់ជំនួយ ស្របពេលដែលស្ថានភាពសង្គម វប្បធម៌ និងប្រពៃណីនៅកម្ពុជាមានលក្ខណៈដោយឡែកពីស្ថានភាពសង្គម វប្បធម៌ និងប្រពៃណីនៅតាមបណ្តាបស្ចិមប្រទេស។ ដោយហេតុដូចនេះហើយទើបប្រមុខរាជរដ្ឋាភិបាលកម្ពុជាធ្លាប់បានលើកឡើងជាការប្រតិកម្មថា «កម្ពុជានឹងមកយកអធិបតេយ្យភាព មកដោះដូរនឹងជំនួយបរទេសនោះឡើយ»។

ក្រៅតែពីលក្ខខណ្ឌជំនួយបើកទូលាយសម្រាប់កម្ពុជា ចិនក៏ជាម្ចាស់ជំនួយធំជាងគេបំផុតរបស់ប្រទេសកម្ពុជាផងដែរ។ ក្នុងរយៈពេលជាង១០ឆ្នាំចុងក្រោយនេះ ចិនជាអ្នកផ្តល់ជំនួយធំជាងគេ សម្រាប់កសាងផ្លូវប្រវែងជាង២០០០គីឡូម៉ែត្រ និងស្ពានធំៗយ៉ាងហោចណាស់៨កន្លែងនៅកម្ពុជា។

## កំណើនវិនិយោគ និងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ

ទំនាក់ទំនងជាមិត្តភាព ការគាំទ្រគ្នាទៅវិញទៅមក រវាងរដ្ឋាភិបាលនិងរដ្ឋាភិបាល ចំណងទំនាក់ទំនងទ្វេភាគីនេះបានរីកចម្រើនជាបន្តបន្ទាប់នាប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ហើយបានធ្វើឱ្យទំហំពាណិជ្ជកម្មសរុបរវាងកម្ពុជានិងចិនបានកើនឡើងយ៉ាងឆាប់រហ័ស ដែលសម្រេចបានជាមធ្យម២៦%ក្នុងមួយឆ្នាំៗក្នុងរយៈពេលជាង១០ឆ្នាំចុងក្រោយនេះ។

ចិនជាប្រទេសវិនិយោគធំជាងគេបំផុតនៅកម្ពុជា ដែលគិតពីដើមទសវត្សរ៍ទី៩០ ដល់ឆ្នាំ២០១៨ ទំហំវិនិយោគរបស់ចិនមានទឹកប្រាក់ជាង១៧ប៊ីលានដុល្លារអាម៉េរិក។ អ្នកវិនិយោគចិនវិនិយោគលើវិស័យមួយចំនួន រួមមាន កម្មន្តសាល សំណង់ វាយនភណ្ឌ និងថាមពលអគ្គិសនី និងប៉ុន្មានឆ្នាំចុងក្រោយនេះ ចិនវិនិយោគលើវិស័យសំណង់ និងអចលវត្ថុកម្ពុជាឈានមុខគេ។

នៅខែមករា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសអំពីគម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះអន្តរជាតិថ្មីមួយនៅក្នុងស្រុកកណ្តាលស្ទឹងខេត្តកណ្តាល ដែលត្រូវបានវិនិយោគរួមគ្នារវាងវិនិយោគិនក្នុងស្រុក និងក្រុមហ៊ុនរបស់ចិន ក្នុងចំនួនទឹកប្រាប់សរុប ១ ៥០០លានដុល្លារសហរដ្ឋអាម៉េរិក។ បន្ថែមពីលើនេះ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសាធារណការនិងដឹកជញ្ជូនកម្ពុជា ក៏កំពុងតែធ្វើការចរចាជាមួយនឹងក្រុមហ៊ុនចិន ក្នុងការស្ថាបនាផ្លូវល្បឿនលឿនមួយខ្សែបន្ថែមទៀត ពីរាជធានីភ្នំពេញទៅទី

ក្រុងបាវិត ខេត្តស្វាយរៀង។ លើសពីនេះទៅទៀត ចិនក៏បានវិនិយោគនៅក្នុងវិស័យទូរគមនាគមន៍កម្ពុជាផងដែរ ដោយបានធ្វើការកប់ខ្សែកាបអុបទិចក្រោមដីប្រវែងប្រមាណ ២ម៉ឺនគីឡូម៉ែត្រ និងបណ្តាញខ្សែកាបអុបទិចក្រោមបាតសមុទ្រ ដែលអាចឱ្យកម្ពុជាតភ្ជាប់ប្រព័ន្ធគមនាគមន៍របស់ខ្លួនទៅក្នុងតំបន់និងពិភពលោក និងក៏អាចជួយជំរុញដល់ការធ្វើពាណិជ្ជកម្មតាមបែប E-Commerce និង អភិបាលកិច្ចតាមបែប E-government ផងដែរ ហើយនេះក៏នឹងផ្តល់នូវលទ្ធភាពងាយស្រួលដល់ក្រុមហ៊ុនពីបរទេសដទៃទៀតសម្រាប់ធ្វើការដាក់ទុនវិនិយោគនៅកម្ពុជាផងដែរ។

នៅចុងឆ្នាំ២០១៨ ក្រុមហ៊ុនធំៗចំនួន៣របស់ចិនបានវិនិយោគលើគម្រោងទីក្រុងរណបថ្មីមួយនៅក្រុងបាវិត ខេត្តស្វាយរៀង ដោយធ្វើការវិនិយោគរួមគ្នាជាមួយនឹងក្រុមហ៊ុនពីរផ្សេងទៀតរបស់កម្ពុជាដើម្បីកសាងទីក្រុងរណបធំជាងគេនៅក្នុងក្រុងបាវិត ខេត្តស្វាយរៀង។ គម្រោងនេះត្រូវបានបើកការដ្ឋាននៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ លើផ្ទៃដីសរុបជាង ១ ០០០ ហិកតា សម្រាប់ការអភិវឌ្ឍនៅដំណាក់កាលទីមួយលើផ្ទៃដី ៥៧ហិកតា ដោយក្នុងនោះមានដូចជា មជ្ឈមណ្ឌលកម្សាន្ត លំនៅឋាន សួនឧទ្យាន តំបន់ឧស្សាហកម្ម ផ្សារទំនើប អាហារដ្ឋាន កាស៊ីណូ អូតែល អគារសម្រាប់លក់ ជួល អគារបណ្តុះបណ្តាល កន្លែងលេងកីឡា និងអគារស្នាក់នៅដ៏ប្រណិតៗ ជាដើម ទីក្រុងរណបថ្មីនេះគ្រោងនឹងចំណាយពេលប្រមាណ ១៥ឆ្នាំ ដើម្បីបញ្ចប់ការសាងសង់។ ក្រៅពីទីក្រុងរណបធំៗទាំងនេះ ក្រុមហ៊ុនចិនបាននិងគ្រោងសាងសង់ទីក្រុងរណបនានានៅតាមបណ្តាខេត្តផ្សេងៗទៀតដូចជា ក្រុងរណបចំនួន២នៅខេត្តកំពង់ចាម ក្រុងរណបចំនួន១នៅខេត្តព្រៃវែង គម្រោងទីក្រុងរណបនៅក្រុងប៉ោយប៉ែត និងគម្រោងវិនិយោគនិងអភិវឌ្ឍន៍ទីក្រុងរណប លើផ្ទៃរាប់រយហិកតារនៅស្រុកបទុមសាគរ និងគិរីសាគរជាដើម។

នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ផ្លូវល្បឿនលឿនពីភ្នំពេញទៅខេត្តព្រះសីហនុ ត្រូវបានបើកការដ្ឋានសាងសង់ជាផ្លូវការក្រោមអធិបតីសម្តេចតេជោនាយករដ្ឋមន្ត្រី ដែលផ្លូវនេះមានប្រវែង១៩០ គីឡូម៉ែត្រ មានទទឹងតួផ្លូវប្រវែង ២៤,៥ម៉ែត្រ ដែលចែកចេញជា៤គន្លង និងចំណាយថវិកាសាងសង់ប្រមាណ២ពាន់លានដុល្លារសហរដ្ឋអាម៉េរិក ដោយប្រើប្រាស់ថវិកាបដិភាគដែលជាហិរញ្ញប្បទានឥតសំណងពិសេសរបស់រដ្ឋាភិបាលចិនប្រមាណ ១៥០លានដុល្លារសហរដ្ឋអាម៉េរិក។ ការសាងសង់ផ្លូវនេះជាការវិនិយោគរបស់ក្រុមហ៊ុនចិនសុទ្ធសាធតាមរូបភាពសាងសង់-ធ្វើអាជីវកម្ម-ផ្ទេរ(BOT) ហើយដីដែលសាងសង់ជាដីដែលក្រុមហ៊ុនបានផ្តល់ថវិកាឱ្យរាជរដ្ឋាភិបាល ដើម្បីទិញដីសម្រាប់សាងសង់ផ្លូវ។

នៅឆ្នាំ២០២២ ការវិនិយោគផ្ទាល់មិនមែនហិរញ្ញវត្ថុរបស់ប្រទេសចិននៅក្នុងប្រទេសកម្ពុជាបានកើនឡើងដល់ ៦៩០ លានដុល្លារក្នុងរយៈពេល១១ ខែដំបូងនៃឆ្នាំ២០២២ ពោលគឺកើនឡើង ៣២.៧ ភាគរយពីមួយឆ្នាំទៅមួយឆ្នាំ។ ចំណែកទំហំពាណិជ្ជកម្មកម្ពុជា-ចិនចាប់ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ ២០២២ មានរហូតដល់ ១៤ ៥០០លានដុល្លារសហរដ្ឋអាម៉េរិក កើនឡើង១៩% ដោយកម្ពុជាបាននាំចេញទៅចិននូវផលិតផលសម្លៀកបំពាក់ ស្បែកជើង ស្បែកសត្វមានរោម ម៉ាស៊ីនប្រើពីស្គុង អង្ករ កៅស៊ូចេក ដំឡូងមី គ្រាប់ស្វាយចន្ទី ស្បែកជើង ហិប វ៉ាលី ជាដើម-ល-។ ខណៈការនាំចូលពីចិនមកវិញ នូវផលិតផលសម្រាប់បម្រើឲ្យការវិនិយោគ និងផលិតកម្ម ដូចជា ក្រណាត់ចាក់ ក្រណាត់ត្បាញពីកប្បាស

គ្រឿងចក្រ ដែក គ្រឿងសំណង់ផ្សេងៗ បរិក្ខារ និងគ្រឿងអេឡិចត្រូនិក វត្ថុធាតុពីប្លាស្ទិក អាលុយមីញ៉ូម គ្រឿងសង្ហារឹម និងក្រដាស និងក្រដាសកាតុងជាដើម។

### ការគាំទ្ររបស់ចិនដល់កម្ពុជាក្នុងនីតិកាលទី៥ និងនីតិកាលទី៦នៃរដ្ឋសភា

ការជាប់គាំងនយោបាយនៅកម្ពុជាក្នុងនីតិកាលទី៥នៃរដ្ឋសភា បានក្លាយទៅជាការព្រួយបារម្ភរបស់សាធារណៈមតិ ប៉ុន្តែទោះជាយ៉ាងនេះក្តី ប្រទេសជប៉ុន អាល្លឺម៉ង់ សហភាពអឺរ៉ុប និងជាពិសេសសាធារណរដ្ឋប្រជាមានិតចិន នៅតែបន្តផ្តល់ជំនួយជាបន្តបន្ទាប់ដល់ប្រទេសកម្ពុជា។

នៅឆ្នាំ២០១៤ ខណៈដែលប្រទេសកម្ពុជាកម្ពុជាកំពុងជួបប្រទះនឹងវិបត្តិនយោបាយដែលបង្កឡើងដោយគណបក្សប្រឆាំង នៅក្នុងបទសម្ភាសន៍ជាមួយនឹងទីភ្នាក់ងារព័ត៌មានស៊ីនហួរ ឯកឧត្តមប្រធានាធិបតីចិន ស៊ី ជិនពីង បានគូសបញ្ជាក់ថា «ប្រទេសចិនជ្រោមជ្រែងប្រជាជនកម្ពុជាឱ្យបន្តដើរតាមវិថីនៃការអភិវឌ្ឍដែលសមស្របទៅនឹងលក្ខខណ្ឌនៃប្រទេសរបស់ខ្លួន»។ ជាមួយគ្នានេះដែរ ឯកឧត្តមបានអំពាវនាវឱ្យបង្កើនការវិនិយោគក្នុងវិស័យកសិកម្ម ទេសចរណ៍ និងការអនុវត្តគម្រោងទាំងឡាយ ទាក់ទងនឹងថាមពលទឹក ធ្យូងថ្ម និងតំបន់សេដ្ឋកិច្ចពិសេសក្នុងប្រទេសកម្ពុជា ព្រមទាំងពង្រីកសហប្រតិបត្តិការផ្នែកវប្បធម៌ និងការផ្លាស់ប្តូរទស្សនកិច្ចយុវជនទៅវិញទៅមកផងដែរ។ ជាការឆ្លើយតប សម្តេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងថា «រដ្ឋាភិបាលនិងប្រជាជនកម្ពុជា វាយតម្លៃខ្ពស់ចំពោះជំនួយរយៈពេលវែងរបស់ចិន ព្រមទាំងពេញចិត្តនឹងចំណងមិត្តភាពរវាងចិននិងកម្ពុជាយ៉ាងខ្លាំង»។ ហើយសម្តេចក៏បានគូសបញ្ជាក់សារជាថ្មីថា «កម្ពុជានឹងបន្តដើរតួក្នុងន័យស្ថាបនា ដើម្បីបង្កើនចំណងមេត្រីភាពរវាងប្រទេសចិន និងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍»។

បន្ទាប់ពីការបោះឆ្នោតថ្នាក់ជាតិនៅកម្ពុជាបានបញ្ចប់រួច នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣ ក្នុងជំនួបរវាង អគ្គស្នងការនគរបាលជាតិ នាយឧត្តមសេនីយ៍ នេត សាវឿន និងមន្ត្រីសមត្ថកិច្ចជាន់ខ្ពស់នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រទេសចិន លោក លី ជូឈុន (Li Zhuqun) ភាគីចិនបានប្រគល់ឱ្យភាគីកម្ពុជា នូវសម្ភារៈជាច្រើន ដើម្បីបង្កើនការពង្រឹងសន្តិសុខ ក្នុងនោះមានអាវុធខ្លី ១៣ន់ដើម គ្រាប់ចំនួន ៥ម៉ឺនគ្រាប់ និងសម្ភារៈសម្រាប់រក្សាសន្តិសុខមួយចំនួនទៀត។

លើសពីនេះទៅទៀត នៅថ្ងៃទី៥ កញ្ញា ឆ្នាំ២០១៧ ក្រសួងការបរទេសចិនបានចេញសេចក្តីថ្លែងការណ៍គាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចាប់ខ្លួនមេដឹកនាំបក្សប្រឆាំង លោក កឹម សុខា ដោយអ្នកនាំពាក្យក្រសួងការបរទេសចិន លោក Geng Shuang បានថ្លែងច្បាស់ៗថា វាជាកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការការពារសន្តិសុខ និងស្ថិរភាពជាតិ។ ក្រសួងការបរទេសចិន បានគាំទ្រចំពោះកិច្ចការនេះ និងសូមធានាដល់កម្ពុជាក្នុងការថែរក្សាសន្តិសុខផ្ទៃក្នុង ហើយប្រទេសចិននឹងជួយសហការជាមួយប្រទេសកម្ពុជានៅគ្រប់កាលៈទេសៈ។ បើកម្ពុជាមានឧបសគ្គណាមួយ ប្រទេសចិននៅពីក្រោយចាំជួយគាំទ្រដំណើរការនេះ ជោគជ័យរបស់កម្ពុជា ក៏ដូចជាជោគជ័យរបស់ប្រទេសចិន ឧបសគ្គកើតឡើងចំពោះប្រទេសកម្ពុជា ក៏ដូចជាឧបសគ្គរបស់ប្រទេសចិនដែរ ភាគីចិនសង្ឃឹមថាប្រទេសកម្ពុជាមានស្ថិរភាពនយោបាយ សេដ្ឋកិច្ចល្អប្រសើរយ៉ាងខ្លាំង នាពេលអនាគត។

ក្នុងដំណើរទស្សនកិច្ចនៅកម្ពុជានៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៧ ឯកឧត្តម Wang Jiarui អនុប្រធានសភាចិន បានជួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយសម្តេចអគ្គមហាពញាចក្រី ហេង សំរិន។ លោក វ៉ាង ជៀរ៉ួយ (Wang Jiarui) បានលើកឡើងថា «*កម្ពុជាមានឧបសគ្គ ចិននៅពីក្រោយចាំជួយគាំទ្រកម្ពុជា ហើយជោគជ័យរបស់កម្ពុជា ក៏ដូចជាជោគជ័យរបស់ចិន ឧបសគ្គរបស់កម្ពុជា ក៏ដូចជាឧបសគ្គរបស់ចិនដែរ*»។

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ ឯកឧត្តម ចាង ការលី ឧបនាយករដ្ឋមន្ត្រីចិន និងឯកឧត្តម សុង ថាវ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងអន្តរជាតិមជ្ឈិមបក្សកុម្មុយនីស្ត ក្នុងជំនួបជាមួយសម្តេចតេជោ ហ៊ុន សែន នៅសាធារណរដ្ឋចិន បានថ្លែងអះអាងថា ចិននឹងបន្តជួយរាល់ទុក្ខលំបាករបស់កម្ពុជាគ្រប់កាលៈទេសៈទាំងអស់ ហើយបន្តរក្សាទំនាក់ទំនង ដោយមិនមានបរទេសណាមកបំបែកបំបាក់ទំនាក់ទំនងកម្ពុជា-ចិនបានឡើយ។ មន្ត្រីជាន់ខ្ពស់ចិនទាំងនេះ ថែមទាំងសន្យាជួបទប់ស្កាត់ និងការពារមិនឱ្យមាន *បដិវត្តន៍ពណ៌* នៅក្នុងប្រទេសកម្ពុជានោះឡើយ។

នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ សម្តេចតេជោនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់នៅលើទំព័រ Facebook របស់សម្តេចថា "*មិត្តចិន គឺជាខ្នងបង្អែកដ៏រឹងមាំរបស់កម្ពុជា ហើយបន្តជួយកម្ពុជាគ្រប់កាលៈទេសៈ*"។ សម្តេចតេជោ ថែមទាំងបញ្ជាក់ថា "*ទំនាក់ទំនងរវាងកម្ពុជានិងចិន ដែលមានរយៈពេលប្រមាណជា ៦០ឆ្នាំហើយនោះ នឹងគ្មានបរទេសណាមកបំបែកបាននោះឡើយ។*"

នៅក្នុងដំណើរទស្សនកិច្ចការងាររបស់សម្តេចតេជោប្រមុខរាជរដ្ឋាភិបាល ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០ ភាគីកម្ពុជា-ចិនបានឯកភាពជំរុញល្បឿននៃការចរចា និងឈានទៅចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ឱ្យបានក្នុងពេលឆាប់ៗខាងមុខ ដើម្បីផ្តល់លទ្ធភាពឱ្យកម្ពុជាមានទីផ្សារកាន់តែធំសម្រាប់ផលិតផលរបស់ខ្លួន។ ថ្នាក់ដឹកនាំចិន បានសន្យាជំរុញឱ្យក្រុមហ៊ុនចិនបង្កើនការវិនិយោគនៅកម្ពុជា និងបន្តផ្តល់ជំនួយដល់ការអភិវឌ្ឍកម្ពុជាឱ្យអស់ពីលទ្ធភាព រួមទាំងការអភិវឌ្ឍនៅក្រុងព្រះសីហនុ។ ជាមួយគ្នានេះ ឯកឧត្តមប្រធានាធិបតីចិនបានប្រកាសស្វាគមន៍ដំណើរទស្សនកិច្ចរបស់សម្តេចតេជោប្រមុខរាជរដ្ឋាភិបាលកម្ពុជាគ្រប់ពេលវេលា ដោយថាសម្តេចអាចអញ្ជើញទៅបំពេញទស្សនកិច្ចនៅប្រទេសចិនពេលណាក៏បាន ហើយឯកឧត្តមប្រធានាធិបតីអាចជួបសម្តេចតេជោច្រើនដងនិងញឹកញាប់ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។ លើសពីនេះទៅទៀត ប្រមុខរដ្ឋចិន បានប្រកាសដោយឥតអល់អែកថានឹងជួយដល់កម្ពុជាគ្រប់កាលៈទេសៈ ដើម្បីជំរុញការអភិវឌ្ឍប្រទេសកម្ពុជាឱ្យកាន់តែរីកចម្រើនទៅមុខបន្ថែមទៀត ហើយលោកក៏បានប្រកាសផ្តល់ជំនួយតាមតម្រូវការសម្រាប់កម្ពុជាដែលជាមិត្តដ៏ស្មោះស្ម័គ្រនេះផងដែរ។ ដំណើរទស្សនកិច្ចរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជានាពេលនេះ គឺជាសញ្ញាណដ៏ល្អមួយ ដែលវាជាការចាប់ផ្តើមនូវសករាជថ្មីមួយទៀត នៃទំនាក់ទំនងរវាងកម្ពុជា-ចិនកម្រិតខ្ពស់បំផុតក្នុងប្រវត្តិសាស្ត្រ ព្រោះវាជាដំណើរទស្សនកិច្ចលើកទីមួយ នៃមេដឹកនាំបរទេសទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ក្នុងខណៈដែលប្រទេសចិនកំពុងប្រឈមមុខនឹងករណីផ្ទុះជំងឺផ្លូវដង្ហើមបង្កដោយវីរុសកូរ៉ូណា។

# សន្និដ្ឋាន

ទំនាក់ទំនងកម្ពុជា-ចិន គឺជាទំនាក់ទំនងជាយុទ្ធសាស្ត្រមួយ ដែលកើតចេញនិងរីកចម្រើនឡើងជាលំដាប់ដោយកត្តាប្រវត្តិសាស្ត្រ ភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច ហើយក៏ជាកត្តាដែលទាញភ្ជាប់ប្រទេសទាំងពីរឱ្យខិតរកគ្នាផងដែរ។ គេអាចនិយាយបានថា សម្តេចព្រះនរោត្តម សីហនុ សម្តេចព្រះបរមរតនកោដ្ឋគឺជាស្ថាបនិកនៃទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ហើយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន គឺជាអ្នកបន្តនិងជំរុញបង្កើននូវទំនាក់ទំនងក្នុងភាពជាដៃគូល្អបន្ថែមទៀតរវាងប្រជាជាតិទាំងពីរ កម្ពុជា-ចិន។ ទំនាក់ទំនងដែលឈានឡើងជាលំដាប់នេះ មិនអាចកាត់ផ្តាច់បានឡើយនូវផលប្រយោជន៍នយោបាយ ដែលចិនបានកំណត់យ៉ាងច្បាស់អំពីគោលការណ៍នៃទំនាក់ទំនងការទូតជាមួយខ្លួនប្រទេសជាដៃគូត្រូវតែគោរពនូវ «នយោបាយចិនតែមួយ»។ ក្រៅពីផលប្រយោជន៍នៃការគាំទ្រនយោបាយចិនតែមួយ កម្ពុជាគឺជាច្រកការទូតយ៉ាងសំខាន់មួយទៅកាន់អាស៊ានសម្រាប់ចិន ដែលសម្លឹងឃើញពីផលប្រយោជន៍ដ៏ធំធេងនៃសមាហរណកម្មតំបន់ និងចង់ជ្រៀតឥទ្ធិពលចូលក្នុងនាមជាមហាអំណាចតំបន់ ក៏ដូចជាពិភពលោក។ ជាមួយគ្នានោះ គេក៏មិនអាចមើលរំលងឡើយអំពីតួនាទីសំខាន់របស់កម្ពុជាក្នុងការសម្របសម្រួលជម្លោះសមុទ្រចិនខាងត្បូង ដែលកម្ពុជាសម្រេចបាននូវសេចក្តីប្រកាសស្តីពីការប្រតិបត្តិសម្រាប់ភាគីជម្លោះក្នុងសមុទ្រចិនខាងត្បូង ក្នុងកិច្ចប្រជុំកំពូលអាស៊ាននៅឆ្នាំ២០០២។ លើសពីនេះទៅទៀត តាមរយៈទំនាក់ទំនងល្អជាមួយកម្ពុជា ចិនក៏ទទួលបាននូវសំឡេងគាំទ្រមួយក្នុងឋានៈកម្ពុជាជាសមាជិកនៃស្ថាប័នអន្តរជាតិ កិច្ចប្រជុំថ្នាក់តំបន់ និងកិច្ចសហប្រតិបត្តិការនានាដូចជា អង្គការសហប្រជាជាតិ អាស៊ាន កិច្ចប្រជុំអាស៊ានបូក៣ កិច្ចប្រជុំអាស៊ាន-ចិន កិច្ចប្រជុំអាស៊ីបូព៌ា កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាន វេទិកាសភាអាស៊ីប៉ាស៊ីហ្វិក យុទ្ធសាស្ត្រគំនិតផ្តួចផ្តើម «ខ្សែក្រវាត់ និងផ្លូវ» និង «ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី» ជាដើម។ ចំណែកឯកម្ពុជា ផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិន បានផ្តល់ឱ្យកម្ពុជានូវផលប្រយោជន៍ជាយុទ្ធសាស្ត្រ ក្នុងនាមចិនជាមហាអំណាចតំបន់និងពិភពលោក ពិសេសគឺផលប្រយោជន៍សេដ្ឋកិច្ចតាមរយៈជំនួយ និងការវិនិយោគដ៏ច្រើនសន្ធឹកសន្ធាប់។ ទំនាក់ទំនងកម្ពុជា-ចិនក្នុងសតវត្សរ៍ទី២១ គឺជាទំនាក់ទំនងជាយុទ្ធសាស្ត្រភូមិសាស្ត្រនយោបាយផង ជាទំនាក់ទំនងក្នុងនាមជាដៃគូគាំទ្រគ្នាទៅវិញទៅមកផង និងជាទំនាក់ទំនងសេដ្ឋកិច្ចស៊ីជម្រៅផងដែរ។ លើសពីនេះ ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការត្បូងពេជ្រ ដែលផ្តោតសំខាន់លើនយោបាយ គឺជាការលើកកម្ពស់ទំនាក់ទំនងរវាងប្រទេសទាំងពីរកាន់តែស៊ីជម្រៅ និងពង្រឹងមិត្តភាពដែកថែបកម្ពុជា-ចិនបន្ថែមទៀត តាមរយៈការប្រើប្រាស់តួនាទីរបស់គណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន ឱ្យបានពេញលេញ ពង្រឹងការផ្លាស់ប្តូរអន្តរភាគីគ្រប់កម្រិត ទាំងក្នុងក្របខណ្ឌរដ្ឋ បក្ស និងយុវជន និងបន្តកសាងសហគមន៍ជោគវាសនារួមកម្ពុជា-ចិន៕